**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៩/០១២/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៨/០១០/២០០៤ កបធ.ច
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញលិខិតលេខ ៣០៤ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )
-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )
-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ
-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៉ិន ឈិន**